ភ្នំពេញ ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩៣

## សេចក្តីសំរេច លេខ : ២៧ សសរ

## ស្តីពីការរៀបចំទីធ្លាមាត់ទន្លេសាបជាប្រយោជន៍សាធារណៈនៅ ក្រុងភ្នំពេញពីកំពង់មុខសួនច្បារផ្សារចាស់មកដល់សួនច្បារមុខ វត្តឧណ្ណាលោម

******

រដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជា

- បានឃើញក្រឹត្យរបស់សម្តេចព្រះឧបយុវរាជ នរោត្តម សីហនុ ព្រះប្រមុខរដ្ឋនៃកម្ពុជា ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជា
- បានឃើញសារាចរលេខ ០១ ស.រ ចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ១៩៩៣ របស់រដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃ កម្ពុជា ស្តីពីកម្មសិទ្ធិស្របច្បាប់របស់ប្រជាពលរដ្ឋបច្ចុប្បន្ន និង កម្មសិទ្ធិសាធារណៈ
- បានឃើញសារាចរលេខ ០២ ស.រ ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ១៩៩៣ របស់រដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃ កម្ពុជា ស្តីពីរបៀបរៀបរយ និង សន្តិសុខសាធារណៈ
- ផ្អែកតាមការចាំបាច់របស់ប្រទេសជាតិ

### សំរេច

**ប្រការ ១ :** រៀបចំទីធ្លាតាមមាត់ទន្លេសាប ជាប្រយោជន៍សាធារណៈ ដែលមានទីតាំងចាប់ពីមុខសួនច្បារផ្សារចាស់រហូតដល់មុខសួនច្បារមុខវត្តឧណ្ណាលោម ដើម្បីអបអរសាទរខួបលើកទី ៤០ នៃទិវាបុណ្យឯករាជ្យជាតិ ដែលនឹងប្រារព្ធធ្វើឡើង ថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ខាងមុខនេះ ។

**ប្រការ ២ :** អង្គភាពរដ្ឋ អាជីវករ និង ពលរដ្ឋ ដែលមានទីតាំងតាមកន្លែងដូចបានជំរាបខាង លើត្រូវរុះរាន រុះរើនិងចាកចេញអោយបានមុនខែ តុលា ឆ្នាំ ១៩៩៣ ជាកំហិត ។

**ប្រការ ៣ :** អភិបាលក្រុងភ្នំពេញ ត្រូវចាត់តាំងការិយាល័យប្រចាំការមួយនៅកន្លែងនោះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅដើម្បី ធ្វើទំនាក់ទំនង ដោយផ្ទាល់ជាមួយអង្គភាព អាជីវករ និង ពលរដ្ឋ ដែលជាប់ពាក់ព័ន្ធនិង កិច្ចការនេះ ។

- អង្គភាព អាជីវករ និង ពលរដ្ឋ ដែលបានបោះទីតាំងក្នុងតំបន់នេះ លើសពី ១ ឆ្នាំ មកហើយ ត្រូវទៅចុះឈ្មោះក្នុងបញ្ជីជំរឿននៅការិយាល័យប្រចាំការ និងត្រូវប្រគល់លិខិតស្នាមផ្សេងៗ ដែលបញ្ជាក់ពីការស្នាក់នៅស្របច្បាប់របស់ខ្លួន ជូនការិយាល័យប្រចាំការ ។

- ការិយាល័យប្រចាំការត្រូវចេញលិខិតមួយប្រកាសពីការទទួលពាក្យទាមទាររបស់សាមីខ្លួន ទុកជាសំណុំរឿងផ្ទាល់ខ្លួន ។

**ប្រការ ៤** : រយៈពេល ៨ ថ្ងៃ បន្ទាប់ពីការប្រគល់លិខិតស្នាមស្របច្បាប់ទាំងឡាយ ជូនការិយាល័យ ប្រចាំការ អភិបាល ក្រុងភ្នំ ពេញត្រូវកំណត់ តំលៃមួយ ដើម្បីសងទៅអ្នក ដែលបាត់បង់ផលប្រយោជន៍ផ្ទាល់ខ្លួន ។ ការកំណត់តម្លៃនេះ គឺធ្វើបាន តែចំពោះអ្នកដែលបានស្នាក់នៅដោយមានការ អនុញ្ញាតិត្រឹមត្រូវមាន លិខិតស្នាម ស្របច្បាប់ និង មានរយៈ ពេលស្នាក់ នៅលើសពី ១ ឆ្នាំ ឡើងទៅ ។

ក្រោយពីទទួលបាននូវតម្លៃបង់ខាតរួចហើយ សាមីខ្លួនត្រូវចុះហត្ថលេខាព្រមព្រៀងនិងត្រូវចាកចេញពីតំបន់ នេះជា បន្ទាន់ហើយសន្យាថា នឹងមិនវិលត្រឡប់មកវិញជាដាច់ខាត ។

**ប្រការ ៥** : ក្នុងករណីមិនព្រមទទួលតំលៃដែលបានកំណត់របស់ អភិបាលក្រុងទេនោះ ការិយាល័យ ប្រចាំការត្រូវរៀបចំសំណុំរឿង បញ្ជូនទៅប្រធានតុលាការ ។ តំលៃមួយសំរាប់ជួសជុលការខូចខាតត្រូវបានទទួលព្រមព្រៀងតាមសាលក្រមរបស់តុលាការ។ចំនួនទឹកប្រាក់តាម តំលៃដែលបានកំណត់ត្រូវប្រគល់ជូនសាមីខ្លួន រយៈពេល ១ អាទិត្យ ក្រោយពេលចាកចេញផុតពីកន្លែងដែលកំណត់ អោយចាកចេញ ។

**ប្រការ ៦** : ចំពោះអ្នកមកស្នាក់នៅគ្មានការអនុញ្ញាតិ រដ្ឋធានីភ្នំពេញ មានវិធានការណ៍ ដាក់ស្តែង តាមលទ្ធភាព ដើម្បីសំ រេចកិច្ចការនេះ ។

**ប្រការ ៧** : ចាប់ពីថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ១៩៩៣ នេះតទៅ តំណាងអភិបាលក្រុងភ្នំពេញ កសាងសំណុំរឿងច្បាស់លាស់បញ្ជូន ទៅតុលាការ ចំពោះអ្នករឹងរូស ។

**ប្រការ ៨** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងសន្តិសុខជាតិ រដ្ឋមន្ត្រីក្រសួងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសាធារណការ រដ្ឋមន្ត្រីនៃបណ្តាក្រសួងពាក់ព័ន្ធ និង អភិបាលក្រុងភ្នំពេញ ត្រូវទទួលអនុវត្ត សេចក្តីសំរេចនេះ អោយមានប្រសិទ្ធិភាព ចាប់តាំងពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខា តទៅ។

**សហប្រធាន**

រដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជា

ព្រះហស្តលេខា-ហត្ថលេខា និង ត្រា

ស្តេចក្រុមហ្លួង **នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**